GC LiFE



# គម្រោងអនាគតក្ដីសង្ឃឹមបុត្រធីតា

## កម្មវត្ថុនៃការធានារ៉ាប់រង

- អាយុជីវិតនៃអ្នកត្រូវបានធានារ៉ាប់រង និងអ្នកស្នើសុំធានារ៉ាប់រង។

## លក្ខខណ្ឌនៃការបង់បុព្វលាភ

| | |
|---|---|
| រយៈពេលបង់បុព្វលាភ | ការបង់រយៈពេល៣ឆ្នាំ ឬការបង់រយៈពេល៦ឆ្នាំ |
| វិធីសាស្ត្របង់បុព្វលាភ | ប្រចាំឆ្នាំ ប្រចាំឆមាស ប្រចាំត្រីមាស ប្រចាំខែ |
| មធ្យោបាយបង់បុព្វលាភ | ការផ្ទេរប្រាក់តាម App ឬគណនីធនាគារ<br>សាច់ប្រាក់ មូលប្បទានបត្រ |
| ការបំពាន | បន្ទាប់ពីការបង់បុព្វលាភធានារ៉ាប់រងលើកទី ១ (មួយ) ការខកខានក្នុងការបង់បុព្វលាភធានារ៉ាប់រងបន្តបន្ទាប់នៅកាលបរិច្ឆេទដល់កាលកំណត់បង់នឹងត្រូវបានចាត់ទុកជាការបំពានលក្ខខណ្ឌបង់បុព្វលាភធានារ៉ាប់រង។ ប្រសិនបើបុព្វលាភធានារ៉ាប់រងនៅតែមិនទាន់បានបង់បន្ទាប់ពីរយៈពេលអនុគ្រោះ (30ថ្ងៃ) ដល់កាលកំណត់ បណ្ណសន្យារ៉ាប់រងនឹងត្រូវផ្អាកសុពលភាព គិតចាប់ពីថ្ងៃបន្ទាប់នៃថ្ងៃផុតកំណត់នៃរយៈពេលអនុគ្រោះ ហើយបណ្ណសន្យារ៉ាប់រងនេះនឹងមិនមានសុពលភាពក្នុងអំឡុងពេលនៃការផ្អាកសុពលភាពនេះឡើយ។ |

## រយៈពេលធានារ៉ាប់រង

- ចាប់ផ្តើមពីកាលបរិច្ឆេទមានសុពលភាពនៃកិច្ចសន្យាធានារ៉ាប់រងរហូតដល់ខួបប្រចាំឆ្នាំរបស់បណ្ណសន្យារ៉ាប់រងនៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងមានអាយុ២២ឆ្នាំ។

## វិសាលភាពនៃការធានារ៉ាប់រង

- ក្នុងអំឡុងពេលដែលបណ្ណសន្យារ៉ាប់រងកំពុងមានសុពលភាព ផលិតផលនេះផ្តល់នូវ៖

  ១.អត្ថប្រយោជន៍លើកលែងបុព្វលាភធានារ៉ាប់រង ក្នុងករណីអ្នកស្នើសុំធានារ៉ាប់រងទទួលមរណភាពដោយគ្រោះថ្នាក់ជាយថាហេតុ

  ២.អត្ថប្រយោជន៍សម្រាប់ការអប់រំ នៅខួបនៃបណ្ណសន្យារ៉ាប់រងដែលអាចទទួលបានអត្ថប្រយោជន៍នោះ។

  ៣.ការការពារលើមរណភាព ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងទទួលមរណៈភាពដោយសារតែជំងឺ ឬគ្រោះថ្នាក់ជាយថាហេតុ។

## អត្ថប្រយោជន៍ធានារ៉ាប់រង

**(១) ការលើកលែងបុព្វលាភធានារ៉ាប់រង**

ក្នុងអំឡុងពេលបង់បុព្វលាភធានារ៉ាប់រង ប្រសិនបើអ្នកស្នើសុំធានារ៉ាប់រងស្លាប់បាត់បង់ជីវិតដោយសារគ្រោះថ្នាក់ជាយថាហេតុ ក្រុមហ៊ុនធានារ៉ាប់រងយល់ព្រមលើកលែងនូវបុព្វលាភធានារ៉ាប់រងលើកក្រោយៗទៀតដែលនឹងត្រូវបង់នៅក្នុងកិច្ចសន្យាធានារ៉ាប់រង។

**(២) អត្ថប្រយោជន៍សម្រាប់ការអប់រំ (បែងចែកជាវិធីសាស្ត្រ៣ A,B,C)**

នៅពេលដែលរយៈពេលបង់បុព្វលាភត្រូវបានបញ្ចប់ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងនៅរស់រានមានជីវិត ចាប់ពីអាយុ ៧ឆ្នាំ ដល់អាយុក្រោម ១៣ឆ្នាំ ក្រុមហ៊ុនធានារ៉ាប់រងនឹងផ្តល់អត្ថប្រយោជន៍សម្រាប់ការអប់រំថ្នាក់បឋមសិក្សា ចំនួន ៣០០ដុល្លារអាមេរិកក្នុងមួយឆ្នាប់នៅរៀងរាល់ខួបនៃបណ្ណសន្យារ៉ាប់រងនីមួយៗ (ចំពោះវិធីសាស្ត្រ B និង C ស្មើ០)។ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងនៅរស់រានមានជីវិត ចាប់ពីអាយុ ១៣ឆ្នាំ ដល់អាយុ ក្រោម ១៩ឆ្នាំ ក្រុមហ៊ុនធានារ៉ាប់រងនឹងផ្តល់អត្ថប្រយោជន៍សម្រាប់ការអប់រំថ្នាក់វិទ្យាល័យចំនួន ៤០០ដុល្លារអាមេរិកក្នុងមួយឆ្នាប់នៅរៀងរាល់ខួបនៃបណ្ណសន្យារ៉ាប់រងនីមួយៗ (ចំពោះវិធីសាស្ត្រ B គឺ ៥០០ដុល្លារអាមេរិកក្នុងមួយឆ្នាប់ និង C គឺ ០)។ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងនៅរស់រានមានជីវិត ចាប់ពីអាយុ ១៩ឆ្នាំ ដល់ថ្ងៃផុតកំណត់នៃរយៈពេលធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងនឹងផ្តល់អត្ថប្រយោជន៍សម្រាប់ការអប់រំថ្នាក់ឧត្តមសិក្សាចំនួន ៥០០ដុល្លារអាមេរិកក្នុងមួយឆ្នាប់នៅរៀងរាល់ខួបនៃបណ្ណសន្យារ៉ាប់រងនីមួយៗ (ចំពោះវិធីសាស្ត្រ B គឺ ៧០០ដុល្លារអាមេរិកក្នុងមួយឆ្នាប់ និង C គឺ ១២០០ ដុល្លារអាមេរិកក្នុងមួយឆ្នាប់)។

**(៣) អត្ថប្រយោជន៍នៅពេលស្លាប់បាត់បង់ជីវិត**

ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងបានស្លាប់បាត់បង់ជីវិតដោយសារតែជំងឺ ឬគ្រោះថ្នាក់ជាយថាហេតុ ហើយមិនធ្លាប់មានសំណងធានារ៉ាប់រងណាមួយត្រូវបានទទួលមុនហេតុការណ៍នោះ ក្រុមហ៊ុនធានារ៉ាប់រងនឹងប្រគល់ត្រឡប់នូវបុព្វលាភដែលអ្នកស្នើសុំបានបង់ ដោយមិនមានការប្រាក់ទៅឲ្យអ្នកស្នើសុំវិញ ហើយកិច្ចសន្យាធានារ៉ាប់រងនឹងត្រូវបញ្ចប់។

## តារាងអត្ថប្រយោជន៍ធានារ៉ាប់រង

| | | |
|---|---|---|
| អាយុ ៧ឆ្នាំដល់ ១២ឆ្នាំ អត្ថប្រយោជន៍ការអប់រំថ្នាក់បឋមសិក្សា | A300<br>B--<br>C-- | USD<br>រៀងរាល់ឆ្នាំ |
| អាយុ ១៣ឆ្នាំដល់ ១៨ឆ្នាំ អត្ថប្រយោជន៍ការអប់រំថ្នាក់វិទ្យាល័យ | A400<br>B500<br>C-- | USD<br>រៀងរាល់ឆ្នាំ |
| អាយុ ១៩ឆ្នាំដល់ ២២ឆ្នាំ អត្ថប្រយោជន៍ការអប់រំថ្នាក់ឧត្តមសិក្សា | A500<br>B700<br>C1200 | USD<br>រៀងរាល់ឆ្នាំ |

ក្នុងករណីអ្នកស្នើសុំធានារ៉ាប់រងទទួលមរណភាពដោយគ្រោះថ្នាក់ជាយថាហេតុ
បុព្វលាភធានារ៉ាប់រងសេសសល់ដែលត្រូវបង់នឹងត្រូវបានលើកលែង។

# បុព្វលាភធានារ៉ាប់រង

រូបិយប័ណ្ណ៖ ដុល្លារអាមេរិក

## តារាងអត្រាបុព្វលាភ

| អាយុរបស់អ្នកត្រូវបានធានា | រយៈពេលបង់បុព្វលាភ | | | | | |
|---|---|---|---|---|---|---|
| | វិធីសាស្ត្រ A | | វិធីសាស្ត្រ B | | វិធីសាស្ត្រ C | |
| | 3ឆ្នាំ | 6ឆ្នាំ | 3ឆ្នាំ | 6ឆ្នាំ | 3ឆ្នាំ | 6ឆ្នាំ |
| 0 | 1,534.66 | 804.71 | 1,323.83 | 694.16 | 1,011.44 | 530.38 |
| 1 | 1,580.73 | 828.85 | 1,363.58 | 714.99 | 1,041.83 | 546.29 |
| 2 | 1,628.28 | 801.28 | 1,404.60 | 736.48 | 1,073.19 | 562.72 |
| 3 | 1,677.29 | 772.91 | 1,446.88 | 758.64 | 1,105.51 | 579.66 |
| 4 | 1,727.81 | 743.71 | 1,490.47 | 781.49 | 1,138.82 | 597.11 |
| 5 | 1,670.47 | 713.65 | 1,535.39 | 805.03 | 1,173.15 | 615.11 |
| 6 | 1,611.42 | 682.68 | 1,581.68 | 829.29 | 1,208.52 | 633.66 |
| 7 | 1,550.59 | 650.78 | 1,629.36 | 854.28 | 1,244.97 | 652.76 |
| 8 | 1,487.93 | 600.44 | 1,678.47 | 792.58 | 1,282.52 | 672.43 |
| 9 | 1,423.38 | 548.58 | 1,729.06 | 729.02 | 1,321.19 | 692.70 |
| 10 | 1,356.88 | 495.15 | 1,781.17 | 663.53 | 1,361.00 | 713.56 |
| 11 | 1,251.90 | 440.10 | 1,652.51 | 596.07 | 1,402.01 | 735.04 |
| 12 | 1,143.75 | 383.39 | 1,519.95 | 526.56 | 1,444.23 | 757.16 |
| 13 | 1,032.33 | 324.97 | 1,383.40 | 454.96 | 1,487.70 | 779.94 |
| 14 | 917.55 | 247.31 | 1,242.72 | 346.23 | 1,532.47 | 593.53 |

**បញ្ជាក់**

ការបង់បុព្វលាភប្រចាំឆមាស = ការបង់បុព្វលាភប្រចាំឆ្នាំ x 0.52
ការបង់បុព្វលាភប្រចាំត្រីមាស = ការបង់បុព្វលាភប្រចាំឆ្នាំ x 0.27
ការបង់បុព្វលាភប្រចាំខែ = ការបង់បុព្វលាភប្រចាំឆ្នាំ x 0.09

ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងបានស្លាប់បាត់បង់ជីវិតដោយសារតែជំងឺ ឬគ្រោះថ្នាក់ជាយថាហេតុ ហើយចំនួនសំណងធានារ៉ាប់រងដែលត្រូវបានទទួលមុនហេតុការណ៍នោះ មានចំនួនតិចជាងបុព្វលាភធានារ៉ាប់រងសរុបដែលបានបង់ ក្រុមហ៊ុនធានារ៉ាប់រងនឹងប្រគល់ត្រឡប់នូវបុព្វលាភដែលអ្នកស្នើសុំបានបង់ដោយមិនមានការប្រាក់ ដកចេញនូវចំនួនសំណងដែលធ្លាប់បានទទួលទៅឲ្យអ្នកស្នើសុំធានារ៉ាប់រងវិញ ហើយកិច្ចសន្យាធានារ៉ាប់រងនឹងត្រូវបញ្ចប់។
ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងបានស្លាប់បាត់បង់ជីវិតដោយសារតែជំងឺ ឬគ្រោះថ្នាក់ជាយថាហេតុ ហើយចំនួនសំណងធានារ៉ាប់រងដែលបានទទួលមុនហេតុការណ៍នោះ គឺមានចំនួនច្រើនជាងឬស្មើនឹងផលបូកនៃបុព្វលាភដែលបានបង់រួច នោះក្រុមហ៊ុនធានារ៉ាប់រងនឹងមិនប្រគល់ត្រឡប់នូវបុព្វលាភដែលបានបង់រួចទៅឲ្យអ្នកស្នើសុំវិញទេ ហើយកិច្ចសន្យាធានារ៉ាប់រងនឹងត្រូវបញ្ចប់។

## ករណីលើកលែង

នៅក្នុងកាលៈទេសៈណាក៏ដោយដូចមានរៀបរាប់ខាងក្រោម ក្រុមហ៊ុនធានារ៉ាប់រងនឹងមិនមានទំនួលខុសត្រូវលើវិសាលភាពនៃការធានាក្នុងប្រការ ៨ នៃ ខ និងលក្ខខណ្ឌធានារ៉ាប់រងក្នុងកិច្ចសន្យាធានារ៉ាប់រងនេះឡើយ បើមានករណីណាមួយដូចខាងក្រោម៖

(១) អ្នកស្នើសុំធានារ៉ាប់រងបានស្លាប់បាត់បង់ជីវិតដោយសារតែជំងឺ ឬធ្វើអត្តឃាត ដោយចេតនាដើម្បីទទួលបានសិទ្ធិលើកលែងចំពោះបុព្វលាភធានារ៉ាប់រងនៅក្រោម ចំនុច (១) ប្រការ ៨ នៃ ខ និងលក្ខខណ្ឌធានារ៉ាប់រងក្នុងកិច្ចសន្យាធានារ៉ាប់រង

(២) អ្នកស្នើសុំធានារ៉ាប់រងដោយសារតែការវាយតប់គ្នា ការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន ការបើកបរក្នុងស្ថានភាពស្រវឹង ការបើកបរក្នុងស្ថានភាពគ្រោះថ្នាក់ ការបើកបរដោយគ្មានបណ្ណបើកបរត្រឹមត្រូវ ឬការបើកបរយានយន្តដោយគ្មានការចុះ បញ្ជីត្រឹមត្រូវដែលបាន កំណត់ដោយច្បាប់ បណ្តាលឲ្យទទួលមរណភាព

(៣) អ្នកស្នើសុំធានារ៉ាប់រងជាប់ពាក់ព័ន្ធនឹងការជ្រមុជទឹក ការលោតឆ័ត្រយោង ការឡើងភ្នំ ការផ្សងព្រេង ការសម្តែងបច្ចេកទេសពិសេស ការប្រណាំងរថយន្ត ដែលបណ្តាលឲ្យទទួលមរណភាព

(៤) ការពិនិត្យមុន និងក្រោយមានផ្ទៃពោះ ការមានផ្ទៃពោះ (រួមមានកូនក្រៅស្បូន) ការរលូតកូន (រួមទាំងការរំលូតកូន) ការសម្រាលកូន (រួមទាំងការសម្រាលកូនដោយវះកាត់) ការពន្យារកំណើត ការវះកាត់មិនឲ្យមានកូន ការព្យាបាលឲ្យមានកូន និងជំងឺផ្សេងទៀតដែលវិវឌ្ឍន៍ចេញពីជំងឺខាងលើនេះរបស់អ្នកស្នើសុំធានារ៉ាប់រង ដែលបណ្តាលឲ្យកើតមានគ្រោះថ្នាក់ស្ថិតក្រោមវិសាលភាពនៃការធានាដូចមានចែងក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ

(៥) អ្នកស្នើសុំធានារ៉ាប់រងទទួលរងនូវឧប្បត្តិហេតុខាងវេជ្ជសាស្ត្រដោយសារការវះកាត់កែសម្ផស្ស ឬការវះកាត់ផ្សេងៗ ដែលបណ្តាលទទួលមរណភាព

(៦) សង្គ្រាម ការប៉ះទង្គិចផ្នែកយោធា ការបះបោរឬការបះបោរប្រដាប់អាវុធ ព្រមទាំងការផ្ទុះនុយក្លេអ៊ែរ ការសាយភាយវិទ្យុសកម្មនុយក្លេអ៊ែរ ឬផលប៉ះពាល់ដោយនុយក្លេអ៊ែរ ដែលបណ្តាលឲ្យអ្នកស្នើសុំធានារ៉ាប់រងទទួលមរណភាព។

យើងខ្ញុំសូមណែនាំឲ្យលោកអ្នកជាវនូវផលិតផល "ធានារ៉ាប់រងបន្ថែមសម្រាប់ជំងឺធ្ងន់ធ្ងរ" និងផលិតផល"ធានារ៉ាប់រងបន្ថែមសម្រាប់ប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យដោយគ្រោះថ្នាក់ជាយថាហេតុ" ដើម្បីទទួលបាននូវការធានាកាន់តែទូលំទូលាយ។

# ចំណាំ៖

ខ្លឹមសារក្នុងខិត្តប័ណ្ណផ្សព្វផ្សាយនេះគឺ
ជាការពណ៌នាដោយសង្ខេប។
សម្រាប់ព័ត៌មានលម្អិតនៃការធានារ៉ាប់រង
រួមមានអត្ថប្រយោជន៍ធានារ៉ាប់រង ករណីមិន
ធានា និងលក្ខខណ្ឌនៃការបញ្ចប់កិច្ចសន្យា
សូមអាន ខ និងលក្ខខណ្ឌធានារ៉ាប់រង។

**ទំនាក់ទំនងមកកាន់យើងខ្ញុំ**


023-989-218 / 098-989-218

service@gc-life.com.kh www.gc-life.com.kh

វ៉នផាក ផ្ទះលេខ A១២ ផ្លូវR៨
ភូមិ ១ សង្កាត់ស្រះចក
ខណ្ឌដូនពេញ រាជធានីភ្នំពេញ